# ឋានានុក្រមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា

*រៀបរៀងដោយ: លោកស្រី **អ៊ឹម សោភណ:** អនុប្រធានការិយាល័យនីតិកម្ម និងវិវាទ*
*លោក **សំ សត្យា** អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល និងនីតិកម្ម*
*លោកបណ្ឌិត **សន ថាន់** អនុប្រធាននាយកដ្ឋានកិច្ចការ រដ្ឋបាល និងនីតិកម្ម*
*ទទួលបន្ទុករួម*

**សេចក្តីផ្តើម:** (Introdution)

ការរៀបចំសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ ឬ ការអនុវត្តច្បាប់ជាដំបូង អ្នកនីតិចាំបាច់ណាស់ត្រូវតែដឹងឲ្យបានច្បាស់អំពីឋានានុក្រមនៃច្បាប់។ ដោយហេតុថា ច្បាប់ទាំងអស់ពុំមានឋានៈឬ ស្ថិតនៅក្នុងលំដាប់ស្មើគ្នាទេ។ លោក HANS KELSEN (១៨៨១-១៩៧៣) ជនជាតិអូទ្រីស និងជាមនុស្សដែលមានឥទ្ធិពលខ្លាំងក្នុងទស្សនៈវិជ្ជាផ្នែកច្បាប់ និងនីតិសាធារណៈ លោកបានកំណត់ថា ច្បាប់ត្រូវតែមានឋានានុក្រមរបស់ខ្លួន ហើយដែលមានលំដាប់ជាសាជី។ មានន័យថាច្បាប់ ឬ បទដ្ឋានគតិយុត្តដែលស្ថិតនៅលំដាប់ទាប ត្រូវគោរពច្បាប់ ឬ បទដ្ឋានគតិយុត្តដែលស្ថិតនៅលំដាប់ខ្ពស់ជាងជានិច្ច និងមិនអាចធ្វើបដិប្បញ្ញត្តិ ឬ និរាករណ៍បទដ្ឋានគតិយុត្តដែលមានលំដាប់ខ្ពស់ជាងបានឡើយ។ ការកំណត់ឋានានុក្រមច្បាប់នេះ គឺជាកត្តាកំណត់ និងអាចចៀសវាងបាននូវការបង្កើតច្បាប់ និងការអនុវត្តច្បាប់ដែលមានលក្ខណៈអនាធិបតេយ្យ។

ការអនុវត្តច្បាប់តាមលំដាប់រាងសាជីនេះ នៅព្រះរាជាណាចក្រកម្ពុជាក៏មានការអនុវត្តតាមលំដាប់ចុះគឺ៖




**១-រដ្ឋធម្មនុញ្ញ:** (Constitution)

នៅព្រះរាជាណាចក្រកម្ពុជារដ្ឋធម្មនុញ្ញគឺជា**ច្បាប់កំពូល**។ ច្បាប់ និងបទដ្ឋានគតិយុត្តដែលស្ថិតនៅលំដាប់ទាបត្រូវតែគោរពតាមរដ្ឋធម្មនុញ្ញជាដាច់ខាត។ បញ្ហានេះ មាត្រា ១៥០ ថ្មីនៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ បានបញ្ញត្តិថា *"រដ្ឋធម្មនុញ្ញជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា"*។ ដូចនេះ ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋត្រូវតែស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។

**២-សន្ធិសញ្ញាអន្តជាតិ:** (International Treaty)

សន្ធិសញ្ញាអន្តរជាតិ ឬ កិច្ចព្រមព្រៀងអន្តរជាតិ គឺជាកិច្ចសន្យាមួយដែលធ្វើឡើងរវាងរដ្ឋមួយ ឬ ច្រើន ដើម្បីបង្កើតកែប្រែ ឬរំលត់កាតព្វកិច្ចមួយ ឬ ច្រើន ហើយដែលកិច្ចការទាំងនេះបានទាក់ទងរវាងរដ្ឋ និងរដ្ឋ។ សន្ធិសញ្ញាអន្តរជាតិ ឬ កិច្ចព្រមព្រៀងអន្តរជាតិមានឋានានុក្រមខ្ពស់ជាង ឬ ទាបជាងរដ្ឋធម្មនុញ្ញរបស់រដ្ឋណាមួយ គឺអាស្រ័យទៅតាមការសម្រេចចិត្តរបស់រដ្ឋនីមួយៗ មានន័យថា បើរដ្ឋនោះយល់ថាសន្ធិសញ្ញាអន្តរជាតិ ឬ កិច្ចព្រមព្រៀងអន្តរជាតិមានផលប្រយោជន៍ដល់រដ្ឋរបស់ខ្លួន ហើយរដ្ឋខ្លួនសម្រេចចិត្តធ្វើការកែប្រែ ឬ វិសោធន៍កម្មរដ្ឋធម្មនុញ្ញរបស់ខ្លួនទៅតាមសន្ធិសញ្ញាអន្តរជាតិ ឬ កិច្ចព្រមព្រៀងអន្តរជាតិនោះ ករណីនេះត្រូវបានគេសន្មតថា សន្ធិសញ្ញាអន្តជាតិ ឬ កិច្ចព្រមព្រៀងអន្តរជាតិរបស់រដ្ឋនោះ មានឋានានុក្រមធំជាង ឬ ខ្ពស់ជាងរដ្ឋធម្មនុញ្ញរបស់រដ្ឋនោះ។ ផ្ទុយទៅវិញ បើរដ្ឋនោះពុំបានធ្វើការកែប្រែ ឬ វិសោធន៍កម្មរដ្ឋធម្មនុញ្ញរបស់រដ្ឋខ្លួនទេ ទោះបីសន្ធិសញ្ញាអន្តរជាតិ ឬ កិច្ចព្រមព្រៀងអន្តរជាតិមានផលប្រយោជន៍ដល់រដ្ឋនោះក៏ដោយ។ ក្នុងករណីនេះ គេចាត់ទុកថាសន្ធិសញ្ញាអន្តរជាតិ ឬ កិច្ចព្រមព្រៀងអន្តរជាតិនោះ មានឋានានុក្រមទាបជាង**រដ្ឋធម្មនុញ្ញ** របស់រដ្ឋនោះ។

ចំពោះព្រះរាជាណាចក្រកម្ពុជា **រដ្ឋធម្មនុញ្ញ**មានតម្លៃខ្ពស់ជាងសន្ធិសញ្ញាអន្តរជាតិ ឬ កិច្ចព្រមព្រៀងអន្តរជាតិ។ មានន័យថា គ្រប់សន្ធិសញ្ញាអន្តរជាតិ ឬ កិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយដែលមិនស្របនឹងគោលការណ៍ រក្សា ការពារ

ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវបានលុបចោល។ ជាក់ស្តែង មាត្រា ២៦ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ បានបញ្ញត្តិថា "*ព្រះមហាក្សត្រទ្រង់ឡាយព្រហស្តលេខាលើសន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ជាអ្នកប្រទានសច្ចាប័នលើសន្ធិសញ្ញា ឬ អនុសន្ធិសញ្ញាអន្តរជាតិទាំងនោះ ក្រោយពីការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភារួច ។*"

**៣-ច្បាប់: (Law)**

ច្បាប់ ស្ថិតក្នុងលំដាប់ក្រោមរដ្ឋធម្មនុញ្ញ។ ច្បាប់ គឺជាវិធានសរសេរមួយដែលមានលក្ខណៈទូទៅ និងអចិន្ត្រៃយ៍។ ច្បាប់ត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិរួមមានៈ រដ្ឋសភា និងព្រឹទ្ធសភា។ ច្បាប់ ករណីរាជរដ្ឋាភិបាលជាអ្នកព្រាង គេឲ្យឈ្មោះថា ៖ **សេចក្តីព្រាងច្បាប់** និងមានឈ្មោះ **សេចក្តីស្នើច្បាប់** ករណីអង្គនីតិជាអ្នកព្រាង។ ច្បាប់មានតម្លៃគតិយុត្តិនៅពេលប្រមុខរដ្ឋដែលជាព្រះមហាក្សត្រ ឬ ជាប្រមុខរដ្ឋ ឬ ប្រធានាធិបតី ឬ ប្រធានក្រុមប្រឹក្សារដ្ឋ (របបកុំមុយនីស្ត) ចុះហត្ថលេខាទទួលស្គាល់ និងបន្ទាប់មកត្រូវចុះក្នុងរាជកិច្ច ដើម្បីប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការតាមរយៈព្រះរាជក្រម ឬ ក្រឹត្យ។ ការតម្រូវបែបនេះ ដោយហេតុថាប្រមុខរដ្ឋជាតំណាងប្រជាពលរដ្ឋទាំងមូលនៅក្នុងរដ្ឋ។ ដូចនេះ ត្រូវតែមាន ការទទួលស្គាល់ជាមុនពីសំណាក់ប្រមុខរដ្ឋមុននឹងដាក់ច្បាប់ណាមួយឲ្យអនុវត្ត។ ច្បាប់ត្រូវបានអ្នកនីតិធ្វើការបែងចែកជា ២ ទៀតគឺ ៖ ច្បាប់រៀបចំអង្គការ ឬ ច្បាប់អង្គីន (Organic Law) និងច្បាប់ធម្មតា (General Law)។

**ក- ច្បាប់រៀបចំអង្គការ ឬច្បាប់អង្គីនៈ (Organic Law)**

ច្បាប់រៀបចំអង្គការ គឺជាច្បាប់ដែលបំពេញបន្ថែមឲ្យរដ្ឋធម្មនុញ្ញ។ ច្បាប់រៀបចំអង្គការ មានតួនាទីសម្រាប់បង្កើតក្រសួង និងរដ្ឋលេខាធិការដ្ឋាន។ មាត្រា ៣៣ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ឆ្នាំ ១៩៩៤ បានបញ្ញត្តិថាៈ "***ការបង្កើតក្រសួង និងរដ្ឋលេខាធិការដ្ឋាន ត្រូវកំណត់ដោយច្បាប់***" ។ ចំណុចសំខាន់មួយទៀតនៃច្បាប់រៀបចំអង្គការ គឺមុននឹងដាក់ប្រកាសឲ្យប្រើប្រាស់ជាផ្លូវការ ច្បាប់នេះ ត្រូវបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យធម្មនុញ្ញភាពបញ្ជាក់ថា ច្បាប់នេះស្របនឹងរដ្ឋធម្មនុញ្ញឬទេ? ក្នុងករណីពិនិត្យទៅមិនស្របនឹងរដ្ឋធម្មនុញ្ញ ច្បាប់នេះពុំអាចអនុវត្តបានទេ។ មាត្រា ១៤២ ថ្មី នៃរដ្ឋធម្មនុញ្ញដដែលបានបញ្ញត្តិថាៈ " *បទប្បញ្ញត្តិក្នុងមាត្រាណា ដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញមិនអាចយកទៅប្រកាសឲ្យប្រើ ឬ យកទៅអនុវត្តបានឡើយ* "។

ច្បាប់រៀបចំអង្គការ ឬ ច្បាប់អង្គីននៅពេលអនុម័តត្រូវមានសំឡេងគាំទ្រដោយមតិភាគច្រើនលើសលុប(២/៣)នៃចំនួនសមាជិកសភាទាំងមូលដោយហេតុថា ការបង្កើតក្រសួង ឬ រដ្ឋលេខាធិការដ្ឋានថ្មី ត្រូវការជ្រើសរើសមន្ត្រីរាជការក្របខ័ណ្ឌថ្មីចូលបម្រើការងារ។ ហេតុនេះ រដ្ឋត្រូវការចំណាយថវិការដ្ឋដែរ។ ដូចនេះ ទើបការអនុម័តត្រូវតែមានសំឡេងភាគច្រើនគាំទ្រ និងការឯកភាពពីសំណាក់ក្រុមប្រឹក្សាធម្មនុញ្ញ។

**ខ-ច្បាប់ធម្មតាៈ (General Law)**

ច្បាប់ធម្មតា គឺជាច្បាប់បំពេញបន្ថែមឲ្យច្បាប់រៀបចំអង្គការ ឬ ច្បាប់អង្គីន។ ច្បាប់ធម្មតា ពុំចាំបាច់មានការពិនិត្យធម្មនុញ្ញភាពដូចច្បាប់រៀបចំអង្គការទេ។ មានន័យថា ច្បាប់ធម្មតាត្រូវការសំឡេងអនុម័តដោយមតិភាគច្រើនដាច់ខាត (៥០+ ១) គឺបានការ។ ច្បាប់ធម្មតា មានតួនាទីរៀបចំ និងគ្រប់គ្រងសណ្តាប់ធ្នាប់សង្គម ឬ សម្រាប់ការការពារ ធនធានធម្មជាតិមានជាអាទិ៍ ច្បាប់ព្រហ្មទណ្ឌ ក្រមនីតិវិធី ព្រហ្មទណ្ឌ ច្បាប់វិនិយោគ ច្បាប់ធនធានទឹក ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីព្រៃឈើ...។ល។ ច្បាប់ធម្មតា ត្រូវបានអ្នកនីតិបន្ត ធ្វើការញែកបន្ថែមទៀតដែរ គឺច្បាប់សាធារណៈ ឬ នីតិសាធារណៈ និងច្បាប់ឯកជន ឬ នីតិឯកជនមានជាអាទិ៍ក្រមរដ្ឋប្បវេណី ច្បាប់ការងារ ក្រឹត្យច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យាជាដើម។ល។

**៤-ព្រះរាជក្រឹត្យៈ (Decret Royal/Royal Decree)**

ព្រះរាជក្រឹត្យ គឺជាសេចក្តីសម្រេចរបស់ប្រមុខរដ្ឋ ដែលជាព្រះមហាក្សត្រតាមការស្នើសុំពីគណៈរដ្ឋមន្ត្រី។ មាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ បានបញ្ញត្តិថាៈ "***ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត។*** " និងមាត្រា ២៨ នៃរដ្ឋធម្មនុញ្ញដដែលបានបញ្ញត្តិទៀតថា : "***ព្រះមហាក្សត្រទ្រង់ឡាយព្រហស្តលេខាលើព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។*** " ព្រះរាជក្រឹត្យ គឺព្រះរាជក្រឹត្យដែលមានលក្ខណៈជា **បទបញ្ជា** និង ព្រះរាជក្រឹត្យមានលក្ខណៈ**ឯកត្តបុគ្គល**។

ព្រះរាជក្រឹត្យដែលមានលក្ខណៈជា **បទបញ្ជា** គឺជាព្រះរាជក្រឹត្យដែលបានដាក់បញ្ញត្តិទូទៅ ពោលមិនសំដៅដល់បុគ្គលណាមួយជាក់លាក់ឡើយ។ ឧទាហរណ៍ ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិអេស្កាប់ ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក ព្រះរាជ

ក្រឹត្យស្ដីពីការបង្កើតក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យ កសិកម្ម និងជនបទ។ល។ ចំណែក ព្រះរាជក្រឹត្យមានលក្ខណៈ **ឯកកត្តបុគ្គល** គឺជាព្រះរាជក្រឹត្យដែលបានដាក់បញ្ញត្តិជាក់លាក់ទៅបុគ្គលណាមួយមានជាអាទិ៍ ព្រះរាជក្រឹត្យស្ដីពីការតែងតាំង ឬ តម្លើងឋានន្តរស័ក្តិ ឬ បញ្ចប់តំណែង។ល។ ព្រះរាជក្រឹត្យដែលមានលក្ខណៈឯកត្តបុគ្គលនេះ ក្នុងករណីបានធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍បុគ្គលណាមួយ ដោយគ្មានមូលហេតុ ច្បាស់លាស់ទេ បុគ្គលរូបនោះ មានសិទ្ធិស្របច្បាប់ក្នុងការប្ដឹងជំទាស់ទៅ នឹងសេចក្ដីសម្រេចដែលជា (ព្រះរាជក្រឹត្យ) នោះវិញបាន ដើម្បីការពារផលប្រយោជន៍ខ្លួន។ មាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ បានបញ្ញត្តិថា: ***"ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិប្ដឹង បរិហារប្ដឹងត៉វ៉ា ឬ ប្ដឹងទារសំណងជួសជុលការខូចខាតដែលបណ្ដាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការ សង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្ដឹងត៉វ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ។"***

ព្រះរាជក្រឹត្យអាចត្រូវបានបង្កើតតាមការចង្អុលរបស់ច្បាប់។ ករណីនេះ ព្រះរាជក្រឹត្យនោះ គឺមានតម្លៃស្មើច្បាប់ ពីព្រោះ អង្គនីតិបញ្ញត្តិបានអនុញ្ញាតឲ្យអង្គនីតិប្រតិបត្តិបង្កើត។ ជាក់ស្ដែង មាត្រា ៨ នៃច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិបានបញ្ញត្តិថា: "*...តំបន់ការពារធនធានធម្មជាតិ...ត្រូវការពារដោយព្រះរាជក្រឹត្យ។* " ប៉ុន្តែ មានព្រះរាជក្រឹត្យមួយចំនួនទៀត ត្រូវបានបង្កើតឡើង តាមការចាំបាច់របស់អង្គនីតិប្រតិបត្តិ ហើយពុំទាន់មានច្បាប់គ្រប់គ្រង។ ឧទាហរណ៍: ព្រះរាជក្រឹត្យស្ដីពីការបង្កើតសហគមន៍នៃសាទ ព្រះរាជក្រឹត្យស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ។ល។និង។ល។

**៥-អនុក្រឹត្យ:** (Anutkret/Sous-Decret/Sub-Decree)

អនុក្រឹត្យ គឺជាសេចក្ដីសម្រេចរដ្ឋបាលដែលមានប្រភពចេញពីគណៈរដ្ឋមន្ត្រី និងចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី។ អនុក្រឹត្យ គឺជាបុព្វសិទ្ធិរបស់នាយករដ្ឋមន្ត្រី ដើម្បីដាក់ចេញឲ្យប្រើប្រាស់ទៅតាមការចាំបាច់របស់រាជរដ្ឋាភិបាល ឬ ករណី ដែលពុំទាន់មានច្បាប់ ឬ ព្រះរាជក្រឹត្យសម្រាប់គ្រប់គ្រង។ មាត្រា ១៣ នៃ ច្បាប់ស្ដី ពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ឆ្នាំ ១៩៩៤ បានបញ្ញត្តិថា ***"នាយករដ្ឋមន្ត្រីចុះហត្ថលេខាលើអនុក្រឹត្យសេចក្ដីសម្រេច និងសារាចររបស់គណៈរដ្ឋមន្ត្រី។ "***

ចំពោះតម្រូវការចាំបាច់សម្រាប់បង្កើតអនុក្រឹត្យ ឬ បង្កើតតាមការអនុញ្ញាតរបស់បទដ្ឋានគតិយុត្តដែលមានលំដាប់ខ្ពស់ជាងនោះ គឺមានភាពប្រហាក់ប្រហែលគ្នាទៅនឹងការបង្កើតព្រះរាជក្រឹត្យដែរ។ ម្យ៉ាងទៀត អនុក្រឹត្យក៏ មានលក្ខណៈជា **បទបញ្ញា** និងលក្ខណៈ **ឯកត្តបុគ្គល** ដូចព្រះរាជក្រឹត្យផងដែរ។ ប៉ុន្តែ ចំណុចខុសគ្នាត្រង់ព្រះរាជក្រឹត្យត្រូវបានចុះហត្ថលេខាដោយព្រះមហាក្សត្រដែលជាប្រមុខរដ្ឋហើយបានបញ្ជូនទៅនាយករដ្ឋមន្ត្រីអនុវត្ត។ ចំណែក អនុក្រឹត្យ វិញ គឺត្រូវចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី ដើម្បីបញ្ជូនទៅរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នដែលមានឋានានុក្រមទាបជាងអនុវត្ត។

**៦-ប្រកាស:** (Prakas-Arrete/Proclamation)

ប្រកាសដែលចេញដោយនាយករដ្ឋមន្ត្រី ជាប្រកាស ដែលបញ្ជាឲ្យក្រសួងច្រើនអនុវត្តតាម។ ប៉ុន្តែក៏មានប្រកាសមួយចំនួនទៀត មានប្រភពចេញពីសមាជិករាជរដ្ឋាភិបាល ដែលដឹកនាំក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន។ ប្រកាសអាចមានប្រកាសរួម ឬ ប្រកាសអន្តរក្រសួង ករណីមានការទាក់ទងក្រសួងច្រើន។ ប្រធានស្ថាប័ន ឬ រដ្ឋមន្ត្រីមានសិទ្ធិចេញប្រកាសដែលទាក់ទងទៅនឹងកិច្ចការក្នុងរង្វង់ក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន ប៉ុន្តែដាច់ខាតត្រូវស្របអនុក្រឹត្យ ឬ សារាចររបស់រាជរដ្ឋាភិបាល (មាត្រា ២៩ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ឆ្នាំ ១៩៩៤)។

ប្រកាសដែលត្រូវបានបង្កើតឡើងតាមការចាំបាច់ ឬ តាមការចង្អុលរបស់បទដ្ឋានគតិយុត្តដែលមានលំដាប់ខ្ពស់ជាងក៏មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងអនុក្រឹត្យដែរ។

**៧-សេចក្ដីសម្រេច:** (Resolution/Decision)

សេចក្ដីសម្រេច គឺជាលិខិតមួយប្រភេទដែលចេញ ដោយរដ្ឋាភិបាល ក្រសួង ស្ថាប័នរាជធានី ខេត្តក្រុង/ស្រុក/ ខណ្ឌ ឬ អង្គការផ្សេងៗ។ ជាទូទៅ ការចេញសេចក្ដីសម្រេច គឺធ្វើឡើងសម្រាប់តែកិច្ចការណាដែលមានសារៈសំខាន់តិចតួច និងមានលក្ខណៈមិនយូរអង្វែង ចំពោះមុខ និងជាកិច្ចការងាយៗ ហើយច្បាស់លាស់។ ប៉ុន្តែ សេចក្ដីសម្រេចអាចធ្វើទៅបាន ដាច់ខាតត្រូវតែផ្អែកលើមូលដ្ឋានច្បាប់ ឬ បទប្បញ្ញត្តិដែលបានប្រគល់ឲ្យ ឬ ធ្វើតាមបញ្ជាពីថ្នាក់លើ។

**៨-ដីកាខេត្ត ក្រុង:** (Deika)

ក្នុងក្របខ័ណ្ឌនៃដែនសមត្ថកិច្ចរបស់ខ្លួន អភិបាល នៃ

គណៈអភិបាលរាជធានី ខេត្ត ក្រុង/ស្រុក/ខណ្ឌ មានសិទ្ធិចេញសេចក្ដីសម្រេចអនុវត្តការងារ របស់ខ្លួនបានតាមរយៈ **ដីកា**។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាតំណាងឲ្យរាជរដ្ឋាភិបាល និងជាស្ថាប័នរដ្ឋបាល ចំណុះឲ្យក្រសួងមហាផ្ទៃ។ ប្រការ ១ នៃប្រកាសស្ដីពីភារកិច្ច សិទ្ធិ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្ត/ក្រុងបានបញ្ញត្តិថា: ***"រដ្ឋបាល ខេត្ត/ ក្រុង នៃព្រះរាជាណាចក្រកម្ពុជាជាស្ថាប័នចំណុះក្រសួងមហាផ្ទៃផ្ទាល់ និងជាតំណាងរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងដែនដីនៃខេត្ត/ក្រុង...។"***

អភិបាល នៃគណៈអភិបាលរាជធានី ខេត្តក្រុង/ស្រុក/ខណ្ឌ គឺមានសមត្ថកិច្ចដឹកនាំ គ្រប់គ្រងលើវិស័យ រដ្ឋបាលនៅក្នុងរង្វង់ដែនដីរបស់ខ្លួនដោយប្រើអំណាចចេញ សេចក្ដីសម្រេច ឬ សេចក្ដីណែនាំ ឬ ដីកាដើម្បីធានាសណ្ដាប់ធ្នាប់សន្តិសុខសាធារណៈ... ប៉ុន្តែ **ដីកា** រាជធានី ខេត្តក្រុង/ស្រុក/ខណ្ឌពុំអាចធ្វើឡើងដោយផ្ទុយទៅនឹងច្បាប់ ឬបទដ្ឋានគតិយុត្តដែលមានឋានានុក្រមលំដាប់ខ្ពស់ជាងបានឡើយ។

**៩-សារាចរ ឬ សារាចរណែនាំ: (Cirulire/Circular or Instruction)**

***សារាចរ:*** គឺជាបទបញ្ជាមួយដែលអង្គភាពថ្នាក់លើបានលើកគោលការណ៍ ឬ វិធានការ ឬ បកស្រាយច្បាប់ ឬវិធានណាមួយ ដើម្បីជាប្រយោជន៍ឲ្យអង្គភាពថ្នាក់ក្រោមអនុវត្ត។

***សារាចរណែនាំ:*** គឺជាអត្ថបទមួយប្រភេទដែលចេញដោយអង្គភាពថ្នាក់លើ ដើម្បីឲ្យអង្គភាពថ្នាក់ក្រោមអនុវត្តបានត្រឹមត្រូវតាមច្បាប់ ឬ វិធានណាមួយ ឬ តាមគោលនយោបាយរបស់ខ្លួនដែលបានដាក់ចេញកន្លងមកឲ្យអនុវត្តតាម ប៉ុន្តែការអនុវត្តនៅពុំទាន់បានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ឬ អនុវត្តមិនចំទិសដៅ និងខ្លឹមសារពិតប្រាកដ។

រួមសេចក្ដីមក សារាចរ ឬ សារាចរណែនាំគឺជាអត្ថបទបទបញ្ជា និងគោលការណ៍ ឬ ជាវិធានរបស់ថ្នាក់លើផ្ដល់មកថ្នាក់ក្រោម ដើម្បីអនុវត្តឲ្យចំទិសដៅ ឬ ខ្លឹមសារគោល-ការណ៍ ឬ វិធាន។ សារាចរ មានគោលបំណង ដើម្បីធ្វើការបកស្រាយបំភ្លឺអត្ថបទច្បាប់ណាមួយដើម្បីអនុវត្តឲ្យបានត្រឹមត្រូវច្បាស់ លាស់ និងឯកភាពគ្នា។ ប៉ុន្តែ សារាចរមានអនុ-ភាពអនុវត្តបានតែចំពោះភ្នាក់ងារសាធារណៈ ដែលស្ថិតនៅក្រោមបង្គាប់របស់ខ្លួនទេ។ ផ្ទុយទៅវិញ សារាចរមិនអាចបង្កើតឡើងសម្រាប់បង្គាប់ប្រជាពលរដ្ឋឲ្យអនុវត្តតាមខ្លួនឡើយ។ ចំណែក អាជ្ញាធរដែលមានសមត្ថកិច្ចចេញសារា-ចរមានជាអាទិ៍ នាយករដ្ឋមន្ត្រី សមាជិក រាជរដ្ឋាភិបាល ឬប្រធានស្ថាប័ន។

**១០-ដីកាឃុំ សង្កាត់: (Deika)**

ដើម្បីអនុវត្តនូវកិច្ចការរបស់ខ្លួនបាន ឃុំ/សង្កាត់ មានសិទ្ធិចេញដីកាដែលមានលក្ខណៈទូទៅ ឬ មានលក្ខណៈឯកត្តភូតដើម្បីគ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទីមុខងារ និងអំណាចរបស់ខ្លួន។ រដ្ឋបាលឃុំ/សង្កាត់ មានតួនាទី២ គឺតួនាទី*បម្រើកិច្ចការមូលដ្ឋាន* និងតួនាទីជា*ភ្នាក់ងាររដ្ឋ* (មាត្រា ៤២ នៃច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់)។

តួនាទីបម្រើកិច្ចការមូលដ្ឋានរួមមាន ធានាសន្តិសុខសណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ សុខភាពសង្គមកិច្ចអភិវឌ្ឍន៍ និងសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ។

ចំណែកតួនាទីជាភ្នាក់ងាររដ្ឋរួមមាន អនុវត្តច្បាប់ ព្រះរាជ-ក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តិរបស់រដ្ឋ។

**សន្និដ្ឋាន: (Conclusion)**

គ្រប់ច្បាប់ និងគ្រប់រដ្ឋទាំងអស់ ទោះបីរដ្ឋនោះមានរបបគ្រប់គ្រងផ្សេងគ្នាក៏ដោយការធ្វើច្បាប់ ការអនុវត្តច្បាប់បានធ្វើឡើងស្របតាមលំដាប់រាង្គសាជីរបស់លោកHANS KELSEN ជានិច្ច។ ផលប្រយោជន៍ឋានានុក្រមច្បាប់គឺ ចៀសវាងបានការរៀបចំច្បាប់ ការអនុវត្តច្បាប់គ្មានភាពអនាធិបតេយ្យ។ មានន័យថា ច្បាប់ ឬ បណ្ដាបទដ្ឋានគតិយុត្ត ដែលលំដាប់ទាប ត្រូវគោរពច្បាប់ ឬ បទដ្ឋានគតិយុត្តដែលមានលំដាប់ខ្ពស់ជាង និងមិនអាចធ្វើបដិប្បញ្ញាត្តិ ឬ និរាករណ៍ ច្បាប់ ឬបទដ្ឋានគតិយុត្តដែលមានលំដាប់ខ្ពស់ជាងបានឡើយ។

ច្បាប់ត្រូវបានអ្នកនីតិកំណត់និយមន័យ ២ យ៉ាងគឺ ៖

**ច្បាប់តាមន័យចង្អៀត :** សំដៅបណ្ដាបទដ្ឋានគតិយុត្តដែលបានអនុម័ត ដោយអង្គនីតិបញ្ញត្តិ។

**-ច្បាប់តាមន័យទូលាយ :** សំដៅបណ្ដាបទដ្ឋានគតិយុត្តដែលមានលំដាប់ចាប់ពីព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសចុះ និងអនុម័តដោយអង្គនីតិប្រតិបត្តិដែលបញ្ហានេះ ត្រូវបានអ្នកនីតិផ្នែករដ្ឋបាលឲ្យឈ្មោះថា សេចក្ដីសម្រេចរដ្ឋបាល។

សេចក្ដីសម្រេចរដ្ឋបាលជាគោលការណ៍ ត្រូវស្របច្បាប់ និងបទដ្ឋានគតិយុត្តដែលមានលំដាប់ខ្ពស់ជាងដាច់ខាត ហើយជនរងគ្រោះដោយសេចក្ដីសម្រេចរដ្ឋបាល គឺមានសិទ្ធិប្ដឹងជំទាស់សេចក្ដីសម្រេចរដ្ឋបាលទៅអាជ្ញាធរដែលចេញសេចក្ដីសម្រេច ឬ អាជ្ញាធរមានលំដាប់ខ្ពស់ ឬ ទៅស្ថាប័ន

តុលាការបាន ដើម្បីជួសជុលព្យសនកម្មដោយសារកើតឡើង អំពីសេចក្ដីសម្រេចរដ្ឋបាលនោះ (មាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣)។ ផ្ទុយទៅវិញ ការបង្កើតព្រះរាជក្រឹត្យ ឬ អនុ-ក្រឹត្យ ឬ ប្រកាសតាមការអនុញ្ញាតអំពីច្បាប់ ឬ បទដ្ឋានគតិយុត្តខ្ពស់ជាង ត្រូវបានអ្នកនីតិសន្មតថា មានតម្លៃស្មើ ច្បាប់ ពីព្រោះ អង្គនីតិបញ្ញាតិបានយល់ព្រម។ រីឯជនរងគ្រោះពុំមានសិទ្ធិប្ដឹងជំទាស់ទៅនឹងសេចក្ដីសម្រេចរដ្ឋបាលប្រភេទនោះបានទេ។ ចំណែកស្ថាប័នតុលាការក៏ពុំមានសិទ្ធិទទួលសំណុំរឿងនេះចាត់ការដែរ។



*រូបលាយយក្សជាប្រភេទឧបករណ៍នេសាទគ្រួសារដែលធ្វើអំពីឫស្សីមួយដើមមានប្រវែងដល់៤ ម៉ែត្រ ប្រើនៅតំបន់មេគង្គលើក្នុងខេត្តក្រចេះ និងស្ទឹងត្រែង*